**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០៦/០៨ របក.អគគ**

# របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ស្នើសុំធ្វើលិខិតឆ្លងដែនផ្លូវការ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "Training Program for Young Leader for Asian Countries for Fiscal Year 2007" នៅប្រទេសជប៉ុនសម្រាប់មន្ត្រីក្រុមគម្រោងកំណែទម្រង់ច្បាប់

-លិខិតអញ្ជើញចូលរួមប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨

-ផ្ញើជីកាអមនៃរបាយការណ៍ស្តីពីកិច្ចប្រជុំលើកទី ១ និងលើកទី ២ អំពីការរៀបចំប្រព័ន្ធសូចនាករ និង ការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ ជូនក្រសួង ស្ថាប័ន និងសមាជិកពាក់ព័ន្ធ

-ផ្ញើជីកាអម នៃឯកសារពាក់ព័ន្ធមួយចំនួន សម្រាប់កិច្ចប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ ជូនសមាជិកពាក់ព័ន្ធ

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីអនុម័តសេចក្តីព្រាងការវិភាគលើលក្ខណៈវិនិច្ឆ័យស្តង់ដារ និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨ នៅសណ្ឋាគារសាន់វេ

-លិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ៤ នៃក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៨

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៨។

**ខ. ការងារកំណែទម្រង់**

-ប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំជាមួយអ្នកឯកទេសអន្តរជាតិពាក់ព័ន្ធនឹងគម្រោងតុលាការគំរូ នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីអនុម័តសេចក្តីព្រាងការវិភាគលើលក្ខណៈវិនិច្ឆ័យស្តង់ដារ និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨ នៅសណ្ឋាគារសាន់វេ

-ប្រជុំអនុក្រុមទី ៤ នៃក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃ ទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំពិភាក្សាជាចុងក្រោយនូវរបាយការណ៍ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យ នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨

-ធ្វើការបណ្តុះបណ្តាលការធ្វើផែនការ និងការគ្រប់គ្រង នៅក្រសួងយុត្តិធម៌ នៅថ្ងៃទី ១២-១៣ ខែកុម្ភៈ ឆ្នាំ២០០៨ និងថ្ងៃទី ១៩-២០ ខែកុម្ភៈ ឆ្នាំ២០០៨។

**គ. ផ្សេងៗ**

-បញ្ជូនមន្ត្រីអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចូលរួមវគ្គ បណ្តុះបណ្តាលស្តីពី ""Training Program for Young Leader for Asian Countries for Fiscal Year 2007" នៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី ២៥ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៨

-ចូលរួមក្នុងសិក្ខាសាលាបូកសរុបលទ្ធផលការងារពន្ធនាគារ នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមពិភាក្សាបញ្ហាមូលនិធិបត់បែន នៅលេខាធិការដ្ឋាន CCJAPIII នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមសិក្ខាសាលាអំពីយុត្តិធម៌កុមារ រៀបចំដោយក្រសួងយុត្តិធម៌ នៅសណ្ឋាគារ សាន់វេ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមប្រជុំពិនិត្យផែនការប្រចាំឆ្នាំ ២០០៨-២០០៩ របស់ CCJAPIII នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨។

**២-សន្និដ្ឋាន**

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុម

ប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីពិនិត្យរបាយការណ៍ប្រចាំឆ្នាំ២០០៧ និងទិសដៅសម្រាប់ឆ្នាំ២០០៨ និងបានរៀបចំប្រជុំបន្តក្រុមការងារបច្ចេក ទេសតុលាការគំរូ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-គ្រោងរៀបចំប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យ ស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន ដោយពិភាក្សាជាមួយ UNDP ដើម្បីឱ្យបន្តជំនួយឧបត្ថម្ភលើគម្រោងនេះ

-រៀបចំឯកសារស្តីពីភាពជឿនលឿននៃកំណែទម្រង់ច្បាប់ និងតុលាការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីផ្ញើជូនលេខាធិការដ្ឋាន GDCC

-រៀបចំឯកសារនានាសម្រាប់វេទិកាផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨

អ្នកធ្វើរបាយការណ៍

**ហ៊្វឹង សុកុល**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**